ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១២៧

ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣

សាលដីកា

លេខ : ២១៤

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី០៦ ខែ តុលា ឆ្នាំ២០០៣ ដោយមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២- លោក ស៊ិន ឌីម ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រម

៤- លោក ប្រាក់ គឹមសាន ជាចៅក្រមរបាយការណ៍

៥- លោក ឈឹម ស៊ីផល ជាចៅក្រម

៦- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៧- លោក យស់ សូខឿន ជាចៅក្រម

៨- លោក ប៉ែន សារឿន ជាចៅក្រម

៩- លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា **ហ៊ុក សុខធុល**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៣៣"ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ រវាង :

ដើមចោទឈ្មោះ **សន សឿន** (ជាចុងបណ្តឹងសាទុក្ខ) អាយុ៤៣ឆ្នាំ ជាតិខ្មែរ ភេទប្រុស របររកស៊ីធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះឡុង សន (ស) ម្តាយឈ្មោះង៉ែត ក្រែង (ស) ប្រពន្ធឈ្មោះទៀង ស៊ីន មានកូន០៥នាក់ ។

ចុងចម្លើយឈ្មោះ **ហោ តាម** (ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៦៣ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ ទីលំនៅភូមប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ហោ ង៉ូវ (ស) ម្ដាយឈ្មោះ កែង នាង (ស) ប្រពន្ធឈ្មោះ ឌី ម៉ូរ មានកូន០១នាក់ ។ ផ្ទេរសិទ្ធិអោយទៅឈ្មោះ **ខៀវ លីណា** ។

មានមេធាវី លោក **នួន លុច** ។

**<u>កម្មវត្ថុបណ្ដឹង</u>** : ប្ដឹងទាមទារដីទំហំ៣៨ម៉ែត្រ គុណ ១២០ម៉ែត្រ

បានឃើញបណ្ដឹងសាទុក្ខលើកទី២ លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោក ខៀវ លីណា ដែលប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណី លេខ៣៣ "ឈ" ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១២៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ដើមចោទឈ្មោះសន សឿន ប្ដឹងទាមទារដីពីឈ្មោះ ហោ តាម ទំហំ១២០ម គុណ១០០ម ដោយអាងហេតុថា ដីនេះខ្លួនបានទិញពីឈ្មោះ ផន ថា ,យឹម អាន និង ភិន ប៉ាច កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៨ ។ លុះមកដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩ តុលាការខេត្តបន្ទាយមានជ័យបានចេញដីកាសំរេចតាមពាក្យស្នើសុំ ដោយសំរេចប្រគល់ដីដែលមានទំហំដូចខាងលើឱ្យឈ្មោះ ហោ តាម គ្រប់គ្រងទៅវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ បានសំរេចសេចក្ដីដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ដើមចោទឈ្មោះសន-សឿន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-បញ្ឈប់សុពលភាពដីកាសំរេចតាមពាក្យស្នើសុំលេខ៤១ ៧ ដស ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩ ចាប់ពីពេលនេះតទៅ ។

៣-ប្រគល់ដីទំនាស់ដែលមាននៅក្នុងគំនូសទីតាំងជាក់ស្ដែងរបស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកអូរជ្រៅ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្ដោយស្របផ្លូវអភិវឌ្ឍន៍ឃុំប៉ោយប៉ែត ប្រវែងបណ្ដោយ១២០ម៉ែត្រគិតពីព្រំប្រទល់ឈ្មោះថាច់ អៃទៅជើង ទទឹងខាងត្បូង៣៨ម៉ែត្រ ទទឹងខាងជើង៤០ម៉ែត្រ អោយដល់ឈ្មោះ សន សឿន ជាដើមចោទតាមការទាមទារ ។

៤-ទុកសិទ្ធិអោយឈ្មោះហោ តាម ទាមទារដីរបស់ខ្លួនដែលបានទិញពីឈ្មោះហាញ់វី

នោះវិញ បានជាដីរាប ។

៥-អោយឈ្មោះហោ តាម សងប្រាក់ប្រដាប់ក្តី៧.០០០រៀល ដែលដើមចោទបានបង់ទុករួចហើយអោយដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រ១ភាគរយលើតំលៃដីសំរបសំរួល ២.០០០.០០០រៀល អត្រាត្រូវបង់ស្មើ ២០.០០០រៀល តាមបញ្ញត្តិច្បាប់ ។

សាលក្រមនេះជំនុំជំរះ ជាសាធារណៈចំពោះមុខគូក្តីទុកសិទ្ធិប្តឹងឧទ្ធរណ៍ពីរខែគិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែមីនា ឆាំ២០០០ របស់ឈ្មោះហោ តាម ប្តឹងមិនសុខចិត្តនឹងត្រង់ចំនុចសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៥ "ក" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០របស់ឈ្មោះហោ តាម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែលើកចោលដោយទាស់ និង គតិច្បាប់ ។

២-តំកល់សាលក្រមលេខ៣៥ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០ របស់តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជី៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល អាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយបើកផ្លូវប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះហោ តាម មិនសុខចិត្តនឹងសាលដីកាលេខ៧៥"ក" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសាលដីកាលេខ០៩"ក" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍បានសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ របស់ឈ្មោះហោ តាម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុស និង គតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ៧៥"ក" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវសាទុក្ខ

ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៧៦ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ របស់លោកខៀវ ស៊ីថា តំណាងអោយលោកហោ តាម ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៧៥"ក" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំនុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៦៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៧៦ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ របស់ឈ្មោះ ខៀវ ស៊ីថា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០៩"ក"ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៥៩ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកខៀវ ស៊ីថា បានបង់ទុកនៅតុលាការកំពូល រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវអោយដើមចោទសងប្រាក់១៩.០០០រៀល នេះទៅចុងចម្លើយវិញ ។

៥-សាលដីកានេះជំនុំជំរះនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ខែវិច្ឆិកា ឆ្នាំ២០០២ និងប្រកាសនាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៣"ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលា-ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍លេខ១១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ ដោយសាលដីកាលេខ២៦៦ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការកំពូល ។

២-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៩ របស់ឈ្មោះសន សឿន ជាដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ប្រគល់ដីទំនាស់ ដែលមានក្នុងគំនូសប្លង់ទីតាំងជាក់ស្តែង របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្តោយស្រប

ផ្លូវ អភិវឌ្ឍន៍ ឃុំប៉ោយប៉ែត ប្រវែងបណ្តោយ១២០ម ទទឹងខាងត្បូង៣៨ម ទទឹងខាងជើង៤០ម ឱ្យទៅឈ្មោះ សន សឿន គ្រប់គ្រង និងកាន់កាប់តទៅ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រ ចំណាយលើការប្រគល់ដីកាកោះ៥.០០០រ និងលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

បង្គាប់ឱ្យឈ្មោះ ហោ តាម បង់ពន្ធសមាមាត្រ១ភាគរយ លើតម្លៃដីទាស់ ។

៥-សាលដីកានេះ ជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ ចំពោះមុខដើមចោទឈ្មោះសន សឿន កំបាំងមុខមេធាវី ប៉ាង សុធា ការពារឱ្យភាគីចុងចម្លើយឈ្មោះ ហោ តាម តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់លោកខៀវ លីណា ដែលប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណី លេខ៣៣ "ឈ" ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៣របស់លោកហោ តាម( ជាម្ចាស់បណ្តឹងសាទុក្ខ) ។

បានឃើញសារណាតប ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៣ របស់លោកសន សឿន ( ជាចុងបណ្តឹងសាទុក្ខ) ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ៣៣"ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និងសំរេច ។

បានស្តាប់ចម្លើយរបស់អ្នកនាង ខៀវ លីណា ( ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : បានជាខ្លួនប្តឹងមិនសុខចិត្ត ព្រោះសាលាឧទ្ធរណ៍បានជំនុំជំរះ ប្រគល់ដីរបស់តាខ្លួនអោយទៅភាគី ម្ខាងទៀត ព្រោះដីនេះជីតាខ្លួនជាអ្នកទិញពីឈ្មោះហាញ់ វី ដោយមានកិច្ចសន្យា និងសាក្សីដឹងលឺត្រឹមត្រូវតាមច្បាប់ ។ កាលពីលោកតាខ្លួនទិញដីនេះ ខ្លួនមានអាយុ១៨ឆ្នាំ ខ្លួនបានដឹងលឺ ហើយមុននឹងធ្វើលិខិតទិលក់ ភាគីបាននាំគ្នាទៅចង្អុលបង្ហាញទីតាំងច្បាស់លាស់ ។ ចំពោះការដែលថា ឈ្មោះហាញ់ វី បានដូរដីអោយតាខ្លួននេះ គឺជាការពុំពិតទេ គឺគ្មានការដោះដូរដីនោះទេ ។ ដីនេះមុនពេលទំនាស់តាខ្លួន

ជាអ្នកកាន់កាប់សព្វថ្ងៃនេះគឺនៅទំនេរ ។ ខ្លួនជាអ្នកបន្តសិទ្ធិពីលោកតារបស់ខ្លួន ឈ្មោះហោ តាម សុំអោយតុលាការជួយរកយុត្តិធម៌អោយខ្លួនផង ព្រោះដីនេះជារបស់តាខ្លួន ។

បានស្តាប់ចម្លើយរបស់លោក សន សឿន (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ខ្លួនបានទិញដីនេះក្នុងខែធ្នូ ឆ្នាំ១៩៩៨ គឺទិញនៅក្នុងក្រុមរបស់ខ្លួនចំងាយពីផ្ទះប្រហែល៧០០ម៉ែត្រ ទៅដីនោះ ហើយមុននឹងខ្លួនទិញដីនោះ ខ្លួនឃើញច្បាស់ថា តា ហាញ់ វី បានលក់ដីច្រលំ ហើយមានការដោះដូរដីអោយតា ហោ តាម ត្រឹមត្រូវហើយទើបខ្លួនទិញ ហើយក្នុងការទិញនេះខ្លួនបានធ្វើច្បាប់ត្រឹមត្រូវ និងមានព្រំប្រទល់ច្បាស់លាស់ ។ ដីនេះខ្លួនបានកាន់កាប់តាំងពីពេលដែលខ្លួនបានទិញរហូតមកស្រាប់តែថ្ងៃមួយខ្លួនក៏បានឃើញមានក្រដាស់លិខិតរបស់ខេត្តដាក់លើដីនេះ ថាអោយតាហោ តាម កាន់កាប់បណ្តោះអាសន្ន ខ្លួនក៏បានដាក់ពាក្យបណ្តឹងទៅតុលាការនេះផង ។ ដីនេះខ្លួនបានទិញពីឈ្មោះ យឹម មាន ឈ្មោះផន ថា និងឈ្មោះភិន ប៉ាច ។ ប៉ុន្តែឈ្មោះភិន ប៉ាច មិនបានផ្តិតមេដៃនេះ គាត់បានប្រគល់សិទ្ធិទៅអោយឈ្មោះយឹម អាន ជាតំណាង ។ សំណូមពរសូមកាន់កាប់ដីនេះ ជាកម្មសិទ្ធិ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ទូត លុច ថាមេធាវីការពារចុងចម្លើយ នាពេលសវនាការថា : ដីទំនាស់នេះជាដីព្រៃស៊ុបទ្រុបហើយលោកហាញ់ វី ជាដីនេះជារបស់ខ្លួន ហើយបានលក់ទៅអោយលោកហោ តាម ក្រោយពីបានទិញតា ហោ តាម បានកាប់ឆ្ការព្រៃ និង គ្រប់គ្រងដីនេះរហូតមក ។ នៅឆ្នាំ១៩៩៨ ក៏មានទំនាស់ជាមួយលោកសន សឿន ថាគាត់បានទិញដីនេះពីឈ្មោះ ភិន ប៉ាច ទៅវិញ ហើយនៅពេលប្តឹងទៅតុលាការ ភិន ប៉ាច បានគេចខ្លួនបាត់ ដូច្នេះគ្មានភស្តុតាង រឹងកសារគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា លោកសន សឿន មានសិទ្ធិកាន់កាប់ដីនេះទេ គឺលោកសន សឿនបានរំលោភយកដីលោកតា ហោ តាម ខុសច្បាប់ ។ គ្មានភស្តុតាងណាបញ្ជាក់ថា ឈ្មោះសន សឿន បានទិញដីនេះពីឈ្មោះ ភិន ប៉ាច ទេ ទាំងសាលដីការបស់តុលាការកំពូល លើកទីមួយ និង របាយការណ៍របស់សាលាឧទ្ធរណ៍មានការយល់ឃើញដូចគ្នា ប៉ុន្តែនៅពេលសំរេចសេចក្តីសាលាឧទ្ធរណ៍បែរជាកាត់មានលក្ខណៈពុំត្រឹមត្រូវទៅវិញ ខ្លួនពុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោលជាអសារបង់ សុំទទួលសិទ្ធិលើដីទំនាស់នេះតាមផ្លូវច្បាប់ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី ចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះ

ខ្សែវ លីណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តី បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចប្រគល់ដីទំនាស់ តាមគំនូសប្លង់របស់ការិយាល័យ រៀបចំនគរូបនីយកម្ម សំណង់និងភូមិបាលស្រុកអូរជ្រៅចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្តោយ១២០ម៉ែត្រទទឹងខាងត្បូង៣៨ម៉ែត្រ ទទឹងខាងជើង៤០ម៉ែត្រ ទៅអោយឈ្មោះសន សឿន កាន់កាប់ និង គ្រប់គ្រងដោយអាងហេតុថា ឈ្មោះហាញ់ វី ដែលជាអ្នកលក់ដីអោយចុងចំលើយ បានអះអាងថា ដីដែលខ្លួនលក់អោយចុងចំលើយនោះពុំមែនជាដីទំនាស់ទេនោះ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា :

+តាមលិខិតផ្ទេរដី ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ១៩៩៧ លោកហាញ់ វី បានផ្ទេរដីទំហំ ២០០ម៉ែត្រគុណ១២០ម៉ែត្រ ស្ថិតនៅភូមិបាលីលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយ-មានជ័យ មានព្រំប្រទល់ខាងលិចទល់នឹងដីឈ្មោះសុវណ្ណ ខាងកើតទល់ផ្លូវ ខាងជើងទល់ឈ្មោះ វិត ខាងត្បូងទល់នឹងឈ្មោះ ថាត់ អៃ ។

+តាមសាក្សីបំភ្លឺ ឈ្មោះថាច់ អៃ ដែលមានព្រំប្រទល់ដីជាប់នឹងដីទំនាស់នេះ ហើយដែលជាសាក្សីក្នុងលិខិតផ្ទេរដី ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៧ បានបញ្ជាក់ថា ដីទំនាស់នេះគឺពិតជាដីដែលឈ្មោះហាញ់ វី បានផ្ទេរឱ្យឈ្មោះហោ តាម ប្រាកដមែន ។

ដូច្នេះចម្លើយផ្ទាល់មាត់របស់លោកហាញ់ វី មិនអាចនាំឱ្យមោឃភាពលិខិតផ្ទេរដីចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៧ បានទេ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍យល់ឃើញតាមចម្លើយរបស់លោកហាញ់ វី ថា លោកហាញ់ វី បានផ្តល់ដីថ្នូរទៅឱ្យលោកហោ តាម រួចហើយ គឺជាការភ័ន្តច្រឡំពីព្រោះថា ក្នុងរឿងក្តីនេះពុំមានភស្តុតាងស្តីពីផ្តល់ដីថ្នូរនេះទេ ហើយចុងចម្លើយក៏បានប្រកែកថា លោកពុំបានទទួលដីថ្នូរនេះដែរ ។

- យល់ឃើញថា លោកសន សឿន ក្តី លោកហោ តាម ក្តីលោកហាញ់ វី ក្តីសុទ្ធតែបញ្ជាក់ថា ពេលខ្លួនទិញលក់ដីនេះ គឺដីនេះជាដីព្រៃនៅឡើយ ។ ប៉ុន្តែតាមសាក្សីបំភ្លឺបានបង្ហាញឱ្យឃើញថា ក្រោយពេលទិញដីហើយ ឈ្មោះហោ តាម បានជួលមនុស្សឱ្យកាប់ឆ្ការហែករានដីនេះ និង បង្កបង្កើនផល ។ ដូច្នេះតាមមាត្រា៦២ និង៧៤ នៃច្បាប់ភូមិបាលចាស់ លោកហោ តាម មានសិទ្ធិលើដីទំនាស់នេះហើយពីព្រោះភាគីដែលអាចមានសិទ្ធិលើដីភោគៈបាន គឺកើតមកពីកិរិយាកាន់កាប់មិនមែនកើតពីការលក់ទិញដីព្រៃទេ ។

- យល់ឃើញថា ការដែលលោកសន សឿន ប្ដឹងទាមទារដីទំនាស់ពីលោក ហោ តាម ដោយអាងហេតុថា លោកបានទិញដីទំនាស់នេះពីឈ្មោះយឹម អាន ឈ្មោះផន ថា និងឈ្មោះភិន ប៉ាច នោះជាការពុំត្រឹមត្រូវទេពីព្រោះថា :

១-ដីទំនាស់នេះស្ថិតនៅលើចំណែកដីដែលលោកអះអាងថា ទិញពីឈ្មោះភិន ប៉ាច ប៉ុន្តែពុំមានកិច្ចសន្យាឬចម្លើយរបស់ឈ្មោះភិន ប៉ាច ដែលបញ្ជាក់ថា អ្នកស្រីពិតជាបានលក់ដីឱ្យលោកទេ ។

២-កិច្ចសន្យាផ្ទេរសិទ្ធិដីដែលមានហត្ថលេខា ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៩៨ របស់លោកមេឃុំឈ្មោះអូ សារឿង ពុំមានស្នាមមេដៃអ្នកស្រីភិន ប៉ាច ទេ ហើយលិខិតនេះក៏ត្រូវបានអភិបាលស្រុកអូរជ្រៅបដិសេធតាមលិខិតលេខ៩៩សជណ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៩ហើយដែរ ។

៣-អ្នកស្រីភិន ប៉ាច ពុំបានចូលខ្លួនមកធានាឱ្យដើមចោទ ចំពោះមុខតុលាការតាមមាត្រា៤៣ នៃក្រឹត្យ-ច្បាប់លេខ៣៨ ក្រ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ទេ ។

៤-កិច្ចសន្យាផ្ទេរសិទ្ធិដីរវាង ឈ្មោះយឹម អាន និងសន សឿន ធ្វើក្រោយការផ្ទេរសិទ្ធិពីឈ្មោះហាញ់ វី និងឈ្មោះហោ តាម ហើយក្រោយការកាប់ឆ្ការ និង បង្កបង្កើនផលរបស់លោកហោ តាម ។ ដូច្នេះដើមចោទពុំអាចមានសិទ្ធិលើដីទំនាស់បានទេ ។

- យល់ឃើញថាពុំមានភស្តុតាងណាបញ្ជាក់ថាឈ្មោះ ភិន ប៉ាច បានកាន់កាប់ដីទំនាស់ទេ មុនលោក ហាញ់ វី លក់ឱ្យលោកហោ តាម និង មុនពេលដែលលោក សន សឿន ទាមទារដីនេះ ។

- យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ៣៣"ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១- ទទួលបណ្ដឹងសាទុក្ខលើកទី២ លេខ១១៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះខៀវ លីណា ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៣៣"ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- ប្រគល់ដីទំនាស់(គំនូសក្រហម) ដែលមាននៅក្នុងគំនូសប្លង់ទីតាំងជាក់ស្ដែងរបស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកអូរជ្រៅ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៩ មានបណ្ដោយស្របផ្លូវអភិវឌ្ឍន៍ ប្រវែងបណ្ដោយ១២០ម៉ែត្រ ទទឹងខាងត្បូង៣៨ម៉ែត្រ ទទឹងខាងជើង៤០ម៉ែត្រ ឱ្យទៅលោកហោ តាម កាន់កាប់ និងគ្រប់គ្រងតទៅ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកហោ តាម បានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យលោកសន សឿន សងប្រាក់១៩.០០០រៀលនេះទៅចុងចម្លើយវិញ ។

- បង្គាប់អោយលោកសន សឿង បង់ពន្ធសមាមាត្រ១ភាគរយៈ លើតម្លៃដីទំនាស់ ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ ។